ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 05 / 2012
ម៉ោង (Time/Heure): 10 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ០៣ ខែ ឧសភា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៦០

រៀបចំដោយ: ដាវ អានសាន និង Faiza ZOUAKRI

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ដាវ អានសាន, លោក Faiza ZOUAKRI, លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វ៉េង ហ៊ិត, លោក Vincent de Wilde d'Estmael, លោក Tarik ABDULHAK។ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI ។ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS។ |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន។ |

00809886



| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក សំ សុគង់, លោក ហុង គីមសួន, លោក វ៉េន ពៅ, លោកស្រី ស៊ិន សូវន, លោកស្រី ជេត វ៉ាន់លី, លោក Barnabé NEKUIE។ |
| សាក្សី៖ ពាន ឃាន (TCW-504) អមដោយមេធាវី លោក ម៉ម រិទ្ធា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោក សាន គីរី, លោកស្រី ពេជ្រ ចរិយា។ |
| ផ្សេងៗ៖ កញ្ញា Zuzana KOVALOVA |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១១.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១១.១៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ | | ១ ម៉ោង ៣០ នាទី |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សំណើសុំពេលវេលាបន្ថែម | តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ | ៩.០០ | ៩.២០ |
| ការបន្តសួរសាក្សី TCW-504 | តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ | ៩.២០ | ១០.៣០ |
| សំណើលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវី អៀង សារី | ១០.៣០ | ១០.៣០ |
| ការពន្យាពេលសវនាការ | អង្គជំនុំជម្រះ | ១១.១៥ | ១១.១៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សំណើសុំពេលវេលាបន្ថែម</u>**

បន្ទាប់ពីការពិគ្រោះជាមួយភាគីនានា អង្គជំនុំជម្រះអនុញ្ញាតតាមសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា ក្នុងការសាកសួរសាក្សី ពាន ឃាន (TCW 504) ដោយអនុញ្ញាតនូវពេលវេលាសាកសួរសាក្សីពេញមួយព្រឹកទៀត។ អង្គជំនុំជម្រះមានពេលវេលាសាកសួរសាក្សីរូបនេះ នៅវេលារសៀល វគ្គទីមួយ។

**ការសាកសួរអំពីសុខភាពសាក្សី**

ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះអំពីសុខភាពរបស់សាក្សី សាក្សីបញ្ជាក់ថា ទោះបីជាមានបញ្ហាសុខភាព សាក្សីនឹងខិតខំឱ្យអស់លទ្ធភាពក្នុងការផ្តល់សក្ខីកម្ម។

**តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តសួរសាក្សី TCW-504**

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបន្តសួរសាក្សី ពាន ឃាន ដោយមានការបង្ហាញឯកសារ។

**ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

មេធាវីការពារក្តី អៀង សារី (ម៉ោង១០.៣០នាទី) ស្នើសុំលះបង់សិទ្ធិឱ្យកូនក្តីរបស់ខ្លួនក្នុងការចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំខាងក្រោមបន្ទប់សវនាការ។ ក្រុមការពារក្តី អៀង សារី បានផ្តល់លិខិតលះបង់សិទ្ធិដល់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង។

**ការពន្យារពេលសវនាការ**

ដោយសារតែសាក្សីមានបញ្ហាសុខភាពធ្ងន់ធ្ងរ អង្គជំនុំជម្រះសម្រេចពន្យាសវនាការលើការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ រហូតដល់ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ ២០១២។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | ចំណើងជើង | ចំណាត់ថ្នាក់ | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/136 | D313/1.2.237 | P 00416593-00416593<br>P 00416593-00416593<br>P 00416593-00416593 | [លិខិតបញ្ជាក់ការជំនួសឯកសារ]<br>Photograph depicting senior leaders at a Party Congress, possibly in 1971<br>[Surrogate Sheet] Photograph depicting senior leaders at a Party Congress, possibly in 1971<br>[Surrogate Sheet] Photograph depicting senior leaders at a Party Congress, possibly in 1971 | P | | | |
| E3/435 | D276/6 | 00373446-00373453<br>00375885-00375891<br>00424121-00424127 | កំណត់ហេតុនៃកាសស្តាប់ចម្លើយសាក្សី (ពាន ឃាន) | P | 00373448 | 00375887 | 00424123 |

| **ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖** |
|---|
| • អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី ចូលរួមដំណើរការសវនាការពីបន្ទប់នៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ និងបង្គាប់ឲ្យមេធាវីផ្ដល់លិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។ <br>• អង្គជំនុំជម្រះសម្រេចពន្យាពេលសវនាការលើការផ្ដល់សក្ខីកម្មរបស់សាក្សី ដោយសារបញ្ហាសុខភាពធ្ងន់ធ្ងររបស់សាក្សី។ <br>• បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២។ |

| **កាលបរិច្ឆេទបន្តសវនាការ៖** |
|---|
| សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បតិ៍ ទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ដាច អានន់ Faiza ZAOUKRI